ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ទូរស័ព្ទ : ( ០២៣) ៤៣០ ៧៤៥
លេខ: ០២០៧ សហវ.សរ

ភ្នំពេញ,ថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ ២០០១

# សារាចរណែនាំ

## ស្តីពី

## ការផ្តល់អាជ្ញាប័ណ្ណចំពោះក្រុមហ៊ុនកាស៊ីណូ

ដោយរង់ចាំច្បាប់សំរាប់គ្រប់គ្រងក្រុមហ៊ុនកាស៊ីណូ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចនៅក្នុងគោលបំណងកែលំអ និងតំរង់ទិសអោយក្រុមហ៊ុនកាស៊ីណូទាំងអស់ ដែលកំពុងធ្វើសកម្មភាព ឬមានបំណងធ្វើអាជីវកម្មកាស៊ីណូអនុវត្តអោយបានត្រឹមត្រូវទៅតាមលក្ខខ័ណ្ឌនានាដូចមានចែង នៅក្នុងអាជ្ញាប័ណ្ណ ។

សារាចរនេះត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋាននៃលិខិតបទដ្ឋានដូចតទៅ :

- បានឃើញព្រះរាជក្រមលេខ ០១.នស. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០
- ចំណាររបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០០០ លើលិខិតរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ៤៩២៦ សហវ.ឧហ ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០០០

# សំ រេ ច

## ជំពូក I

## បទបញ្ញត្តិទូទៅ

**ប្រការ ១ : កម្មវត្ថុ**

កម្មវត្ថុនៃសារាចរនេះ គឺបង្កើតអោយមានប្រព័ន្ធមួយសំរាប់ចេញអាជ្ញាប័ណ្ណការគ្រប់គ្រង និង ការត្រួតពិនិត្យកាស៊ីណូ និងការលេងល្បែងក្នុងកាស៊ីណូសំដៅ :

ក.ជំរុញអោយមានការវិវឌ្ឍន៍ក្នុងវិស័យទេសចរណ៍ ផ្តល់ការងារអោយប្រជាពលរដ្ឋ និងកិច្ច អភិវឌ្ឍន៍ក្នុងតំបន់ ។

ខ.ធានាបញ្ជាក់ថា ការគ្រប់គ្រង និងការប្រតិបត្តិកាស៊ីណូ ប្រព្រឹត្តទៅប្រកបដោយភាព ស្មោះត្រង់ និងសុវត្ថិភាព ។

គ.ធានាបញ្ជាក់ថា មានតែបុគ្គលដែលកាន់លិខិតឆ្លងដែនបរទេសតែប៉ុណ្ណោះ ដែលត្រូវបាន អនុញ្ញាតអោយចូលលេងល្បែងក្នុងកាស៊ីណូ ។

ឃ.បង្កើនប្រាក់ចំណូលក្នុងថវិការដ្ឋ ។

**ប្រការ ២ : និយមន័យ**

ក.ពាក្យ "**កាស៊ីណូ**" សំដៅដល់ទីតាំងនៃអាគារសណ្ឋាគារកាស៊ីណូចំរុះ (Hotel-Casino Complex) ជាកន្លែងសំរាប់ការលេងល្បែង ជាកន្លែងសំរាប់រាប់លុយ ការឃ្លាំមើលគណនេយ្យ ការ ស្តុកអីវ៉ាន់ និងសកម្មភាពផ្សេងៗទៀត ដែលទាក់ទងដល់កិច្ចប្រតិបត្តិការ និងដំណើរការកាស៊ីណូ ។

ខ.ពាក្យ " **អាជ្ញាប័ណ្ណបើកកាស៊ីណូ** "សំដៅដល់អាជ្ញាប័ណ្ណដែលផ្តល់ដោយរដ្ឋមន្ត្រី ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុញ្ញាតអោយបើក និងលេងល្បែងស៊ីសងនៅក្នុងកាស៊ីណូស្របទៅតាមច្បាប់ និងការអនុញ្ញាតរបស់រាជរដ្ឋាភិបាល។

## ជំពូក II

## នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាប័ណ្ណ

**ប្រការ ៣ :** ពាក្យសុំអាជ្ញាប័ណ្ណ ត្រូវស្នើដោយបុគ្គលដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ ( អ្នកចាត់ការ ឬជនដែលបានទទួលសិទ្ធិជាលាយល័ក្ខអក្សរ ) ស្របតាមបញ្ញត្តិដូចមានរៀបរាប់ខាងក្រោមនេះ :

ក.នាម ឬនាមករណ៍របស់ក្រុមហ៊ុន

ខ.ផ្លាកសញ្ញារបស់ក្រុមហ៊ុន (Logo)

គ.ទំហំអាជីវកម្ម និងទំហំផ្ទៃក្រឡាអាគារក្រុមហ៊ុនដោយគិតជាតំលៃ

ឃ.ចំនួនប្រភេទល្បែង ចំនួនតុល្បែង និងសំភារៈល្បែង

ង.ថ្ងៃ ខែ ឆ្នាំ ដែលក្រុមហ៊ុនចាប់ផ្តើមធ្វើអាជីវកម្ម

ច.ចំនួនម៉ោងបើក ក្នុងមួយសប្តាហ៍

ឆ.អាស័យដ្ឋាននៃទីស្នាក់ការកណ្តាល ឬសាខានៅកម្ពុជាក្នុងករណីជាក្រុមហ៊ុនបរទេស

ជ.ចំនួនមូលធនតំកល់ទុកក្នុងបេឡាក្រុមហ៊ុនសំរាប់ទូទាត់ល្បែងស៊ីសង

ឈ.ចំនួនដើមទុនដែលមានស្រាប់ ឬ ដើមទុនដែលបានវិនិយោគ

ញ.លិខិតបញ្ជាក់អំពីការតំកល់ដើមទុនចេញដោយធនាគារជាតិ នៃកម្ពុជា

ដ.ការបែងចែកភាគហ៊ុន និងសិទ្ធិបោះឆ្នោត និងកិច្ចព្រមព្រៀងដែលអាចមានរវាងភាគទុនិកៈ ដែលដើរតួនាទីក្នុងការដឹកនាំគោលនយោបាយរបស់កាស៊ីណូ ( អាជ្ញាប័ណ្ណស្តីពីការចុះបញ្ជីពាណិជ្ជកម្ម ) ។

ឋ.អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិចបំផុតពីររូប (០២ រូប)ដែលទទួលខុសត្រូវក្នុងការដឹកនាំ អោយមានប្រសិទ្ធភាពនូវសកម្មភាពអាជីវកម្មរបស់កាស៊ីណូ ។ អ្នកចាត់ចែងដែលបានទទួលការ តែងតាំងរួចហើយ ត្រូវផ្តល់ពត៌មានដូចបានរៀបរាប់ក្នុងប្រការ ៤ នៃសរាចរនេះ ហើយផ្តល់នូវ លិខិតថ្កោលទោសមួយច្បាប់ ។ ចំពោះអ្នកចាត់ចែងជាជនបរទេសដែលមានលំនៅដ្ឋាននៅកម្ពុជាតិច ជាងបីឆ្នាំ (០៣ ឆ្នាំ) លិខិតថ្កោលទោសនេះ ត្រូវជំនួសដោយឯកសារចេញដោយអាជ្ញាធរមាន សមត្ថកិច្ច នៃប្រទេសដើមរបស់ខ្លួន ដោយបញ្ជាក់ថា ជនដែលមានពាក់ព័ន្ធមិនត្រូវបានហាមឃាត់ មិនអោយចាត់ចែងក្នុងគ្រឹះស្ថានហិរញ្ញវត្ថុណាមួយ តាមខ្លឹមសារនៃបទបញ្ញត្តិរបស់ប្រទេសនោះទេ ។

ឌ.ត្រូវរៀបរាប់អំពីទ្រង់ទ្រាយ ទិសដៅ និងកម្មវិធីផែនការសកម្មភាពអាជីវកម្មកាស៊ីណូ ដោយបញ្ជាក់អំពី :

១.ទីតាំងភូមិសាស្ត្ររបស់ក្រុមហ៊ុនអាជីវកម្ម

២.ប្រភេទល្បែង និង ប្រព័ន្ធគ្រប់គ្រងល្បែងនៅក្នុងក្រុមហ៊ុន

៣.ប្រភពធនធានហិរញ្ញវត្ថុ ដែលបានគ្រោងទុក :

-មូលនិធិផ្ទាល់

-មូលប័ត្រឥណទេយ្យ ដែលអាចជួញដូរបាន

-ប្រាក់កម្ចីលើទីផ្សារអន្តរធនាគារជាដើម

៤.ចំនួនបុគ្គលិកដែលបានបំរើការក្នុងក្រុមហ៊ុន រួមទាំងបុគ្គលិកជាជនបរទេស និង បញ្ជីបើកបៀវត្ស ដោយរាយលំអិតតាមប្រភេទបុគ្គលិក ។

៥.សេវាកម្មផ្សេងៗទៀតដែលបំរើអោយអាជីវកម្មក្រុមហ៊ុន

**ប្រការ ៤ :** បុគ្គលម្នាក់ក្នុងចំណោមបុគ្គលពីររូប (០២រូប) ដែលត្រូវបានតែងតាំងក្នុងមុខតំណែងគ្រប់គ្រង ដូចជាការទទួលខុសត្រូវក្នុងការដឹកនាំអាជីវកម្មកាស៊ីណូអោយមានប្រសិទ្ធភាព ត្រូវផ្តល់ពត៌មាន ដោយបំពេញជីវប្រវត្តិដូចខាងក្រោមនេះ :

ក.អត្តសញ្ញាណរបស់នាយកចាត់ការ :

-នាម និងគោត្តនាម ឬ របសស្សនាម

-ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត

-សញ្ជាតិ

-អាស័យដ្ឋានផ្ទាល់ខ្លួន ( ត្រូវមានកន្លែងស្នាក់នៅជិតកន្លែងធ្វើអាជីវកម្ម ដូចជានៅក្នុងប្រទេសកម្ពុជា )

ខ.គុណវឌ្ឍិ និងបទពិសោធន៍ :

-សញ្ញាប័ត្រ និងថ្ងៃ ខែ ឆ្នាំ ទទួលសញ្ញាប័ត្រ ( បើមាន)

-មុខតំណែងដែលបានកាន់កាប់ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ ដោយមានឈ្មោះទីកន្លែង និងសកម្មភាពនិយោជក ប្រភេទបទពិសោធន៍ទទួលបាន និងកិរិតទទួលខុសត្រូវ ។

គ.រៀបរាប់ពីភារកិច្ចគ្រប់គ្រង ដែលនាយកចាត់ការទទួលខុសត្រូវដោយផ្ទាល់ ។

ឃ.បញ្ជាក់ថា តើនៅកម្ពុជា ឬនៅបរទេសខ្លួនធ្លាប់បានទទួលរងនូវទណ្ឌកម្មតាមនីតិវិធីរដ្ឋបាល ឬតុលាការឬទេ ? ត្រូវរាយលំអិតនូវពតិមានទាំងអស់អោយបានសមស្រប ។

ង.បញ្ជាក់ថា តើខ្លួនធ្លាប់បានទទួលរងនូវវិន័យ ឬការបណ្តេញចេញពីនិយោជកណាមួយដែរឬទេ ? បើមានត្រូវរាយលំអិតនូវពតិមានដែលពាក់ព័ន្ធទាំងអស់ ។

## ជំពូក III

## អាជ្ញាប័ណ្ណកាស៊ីណូ និងលក្ខខ័ណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណ

**ប្រការ ៥ :** អាជ្ញាប័ណ្ណកាស៊ីណូ :

ក.រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នកផ្តល់អាជ្ញាប័ណ្ណកាស៊ីណូអោយម្ចាស់កាស៊ីណូតាមសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល នៅពេលដែលលក្ខខ័ណ្ឌក្នុងសារាចរនេះត្រូវបានបំពេញរួចហើយ ។

ខ.ការផ្តល់អាជ្ញាប័ណ្ណគឺជាការផ្តល់ទិដ្ឋាការបច្ចេកទេស ។ ក្រុមហ៊ុនកាស៊ីណូទាំងអស់ ដែលបានទទួលអាជ្ញាប័ណ្ណរួចហើយ ទើបមានសិទ្ធិតាមផ្លូវច្បាប់ក្នុងការប្រកបអាជីវកម្មរបស់ខ្លួន ។

គ.ការចាត់ចែងល្បែងស៊ីសងកាស៊ីណូដោយបុគ្គលណាម្នាក់ ដែលគ្មានអាជ្ញាប័ណ្ណកាស៊ីណូត្រូវហាមឃាត់ ។

ឃ.ក្នុងករណីគ្មានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ម្ចាស់កាស៊ីណូមិនត្រូវធ្វើកិច្ចព្រមព្រៀងដំណើរកាស៊ីណូជាមួយបុគ្គលដទៃទៀត ដើម្បីអោយបុគ្គលនោះចាត់ចែងការងារក្នុងអាគារសណ្ឋាគារ-កាស៊ីណូចំរុះ ឬ កាស៊ីណូទេ ។

ង.អាជ្ញាប័ណ្ណកាស៊ីណូអសុពលភាពក្នុងករណី :

១.អាជ្ញាប័ណ្ណកាស៊ីណូត្រូវបានលុបចោល ឬ ព្យួរទុក

២.រយៈពេលសុពលភាពនៃអាជ្ញាប័ណ្ណកាស៊ីណូត្រូវបានបញ្ចប់

**ប្រការ ៦ :** លក្ខខ័ណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណកាស៊ីណូ :

ក.អាជ្ញាប័ណ្ណកាស៊ីណូត្រូវបានផ្តល់អោយនៅពេលដែលបុគ្គលស្នើសុំអាជ្ញាប័ណ្ណកាស៊ីណូ បំពេញនូវរាល់លក្ខខ័ណ្ឌដូចខាងក្រោមនេះ :

១.អ្នកស្នើសុំផ្តល់អាជ្ញាប័ណ្ណកាស៊ីណូ ជាម្ចាស់អាគារសណ្ឋាគារ-កាស៊ីណូចំរុះ ។

២.ពាក្យស្នើសុំផ្តល់អាជ្ញាប័ណ្ណកាស៊ីណូត្រូវធ្វើជាលាយល័ក្ខអក្សរមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានភ្ជាប់មកជាមួយនូវសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ស្តីពីការអនុញ្ញាតឱ្យបើកកាស៊ីណូផង ។

៣.ម្ចាស់អាជ្ញាប័ណ្ណកាស៊ីណូ និងបុគ្គលដទៃទៀត ត្រូវបំពេញអោយបានគ្រប់គ្រាន់នូវលក្ខណៈសម្បត្តិដូចមានចែងក្នុងប្រការ ៧ នៃសារាចរនេះ ។

**ប្រការ ៧ :** ម្ចាស់អាជ្ញាប័ណ្ណកាស៊ីណូ និងបុគ្គលដទៃទៀតត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

ក.មានកេរ្តិ៍ឈ្មោះល្អ

ខ.មានប្រភពធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ អាចធានាដល់ស្ថេរភាពក្នុងដំណើរការរបស់អាគារសណ្ឋាគារ-កាស៊ីណូចំរុះ ។

គ.ក្នុងករណីម្ចាស់អាជ្ញាប័ណ្ណកាស៊ីណូជានីតិបុគ្គល ត្រូវមានបែបបទគ្រប់គ្រាន់ស្តីពីរចនាសម្ព័ន្ធកម្មសិទ្ធិ ឬរចនាសម្ព័ន្ធចាត់តាំង ។

ឃ.មានបទពិសោធន៏ និងសមត្ថភាពជំនាញគ្រប់គ្រាន់ ដើម្បីធានាដល់ការគ្រប់គ្រង និងដំណើរការអាគារសណ្ឋាគារ-កាស៊ីណូចំរុះ ។

**ប្រការ ៨ :** ក្នុងករណីផុតសុពលភាពនៃអាជ្ញាប័ណ្ណ ហើយក្រុមហ៊ុនមិនបានមកបំពេញបែបបទជាថ្មីតាមការកោះអញ្ជើញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងនឹងដកហូតជាបណ្តោះអាសន្ន ឬលុបចោលជាស្ថាពរនូវអាជ្ញាប័ណ្ណ (Licence) ដែលបានផ្តល់អោយក្រុមហ៊ុនទាំងនោះ ។

**ប្រការ ៩ :** ចំពោះក្រុមហ៊ុនដែលបានទទួលអាជ្ញាប័ណ្ណរួចហើយ (Licence) ហើយមានបំណងពង្រីក ឬបង្រួមទំហំអាជីវកម្ម និងបន្ថែម ឬ បន្ថយចំនួនតុល្បែង និងប្រភេទល្បែងថ្មី ត្រូវស្នើសុំលិខិតអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាថ្មី ។ ក្នុងករណីមិនអនុវត្តតាមនេះ ក្រុមហ៊ុននឹងត្រូវទទួលរងនូវការផាកពិន័យទៅតាមច្បាប់ជាធរមាន ឬត្រូវដកហូតអាជ្ញាប័ណ្ណជាស្ថាពរ ។

**ប្រការ ១០ :** ចំពោះក្រុមហ៊ុនដែលបានលក់ ទិញ ឬ ផ្ទេរទៅអោយក្រុមហ៊ុនផ្សេងទៀតបន្តធ្វើអាជីវកម្មដោយគ្មានការអនុញ្ញាត នោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងដកហូតអាជ្ញាប័ណ្ណ ហើយនឹងចេញលិខិតបញ្ឈប់អាជីវកម្មជាស្ថាពរ ។

**ប្រការ ១១ :** ចំពោះក្រុមហ៊ុនដែលគ្មានអាជ្ញាប័ណ្ណ (Licence) ហើយកំពុងធ្វើសកម្មភាពអាជីវកម្មត្រូវរួសរាន់រៀបចំសំណុំបែបបទស្នើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលមួយខែ ក្រោយពីសេចក្តីជូនដំណឹងនេះចូលជាធរមាន ។

## ជំពូក IV
## ថេរវេលារបស់អាជ្ញាប័ណ្ណ

**ប្រការ ១២ :** អាជ្ញាប័ណ្ណនេះត្រូវបានផ្តល់អោយមានរយៈពេលមួយឆ្នាំ (០១ឆ្នាំ) គិតចាប់ពីថ្ងៃចុះហត្ថលេខាលើអាជ្ញាប័ណ្ណតទៅ ។ នាយកក្រុមហ៊ុនកាស៊ីណូទាំងអស់ដែលកំពុងធ្វើសកម្មភាពអាជីវកម្ម និងកំពុងសាងសង់អាគារកាស៊ីណូត្រូវរូតរះរៀបចំសំណុំលិខិតដូចមានចែងក្នុងប្រការ៣នៃសារាចរនេះមិនអោយហួសរយៈពេល៣០ថ្ងៃ បន្ទាប់ពីសារាចរនេះចូលជាធរមាន ។ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណមានបំណងចង់បន្តរយៈពេលអាជ្ញាប័ណ្ណជាថ្មីទៀត ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនអោយលើសពីរយៈពេលបីខែ(០៣ខែ) មុនពេលផុតសុពលភាពនៃអាជ្ញាប័ណ្ណដែលកំពុងប្រើប្រាស់ ។ ក្នុងករណីមិនបានដាក់ពាក្យស្នើសុំបន្តតាមកាលកំណត់ខាងលើនេះទេ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើការផាកពិន័យជាប្រាក់ចំនួនមួយលានរៀល (១.០០០.០០០រៀល ) ក្នុងមួយថ្ងៃ រហូតដល់ថ្ងៃបានដាក់ពាក្យស្នើសុំនេះ ។

## ជំពូក V
## ថ្លៃអាជ្ញាប័ណ្ណកាស៊ីណូ

**ប្រការ ១៣ :** ក.ម្ចាស់អាគារសណ្ឋាគារ-កាស៊ីណូចំរុះ និងសាខារបស់ខ្លួនត្រូវបង់ថ្លៃអាជ្ញាប័ណ្ណ ចំនួនមួយរយម្ភៃលានរៀល (១២០.០០០.០០០,០០រៀល) សំរាប់អាគារសណ្ឋាគារ-កាស៊ីណូចំរុះនីមួយៗ ដើម្បីទទួលបាននូវអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ខ.ក្រុមហ៊ុនត្រូវបង់ចំនួនសែសិបលានរៀល (៤០.០០០.០០០,០០រៀល) សំរាប់ការសុំពង្រីកបន្ថែម ឬ សុំប្តូរប្រភេទល្បែងថ្មី ។

គ.និងបង់ចំនួនមួយរយលានរៀលទៀត (១០០.០០០.០០០,០០រៀល) ចំពោះការផ្ទេរ ឬលក់អាជ្ញាប័ណ្ណពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយទៀត ។

ឃ.ក្នុងករណីមិនបង់ប្រាក់តាមកាលកំណត់ទេ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនចេញអាជ្ញាប័ណ្ណឱ្យធ្វើអាជីវកម្មឡើយ ។

## ជំពូក VI
## ការលុបចោល និងការព្យួរទុកអាជ្ញាប័ណ្ណកាស៊ីណូ

**ប្រការ ១៤ :** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិលុបចោល ឬព្យួរទុកអាជ្ញាប័ណ្ណទៅតាមប្រព្រឹត្តិ - ការណ៍ និងដំណោះស្រាយទាំងឡាយដែលអ្នកទទួលអាជ្ញាប័ណ្ណពុំបានឆ្លើយតបក្រោយរយៈពេល សាមសិបថ្ងៃ (៣០ថ្ងៃ) ទៅនឹងសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សររបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីដោះស្រាយទៅលើការមិនគោរព និងមិនអនុវត្តតាមលក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណដូច ខាងក្រោម :

ក.អ្នកទទួលអាជ្ញាប័ណ្ណពុំបានអនុវត្តតាមលក្ខខ័ណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណ ដូចមានចែងក្នុង ប្រការ ១៣ នៃសារាចរនេះ ឬ មិនគោរពតាមការណែនាំផ្សេងៗរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ខ.អ្នកទទួលអាជ្ញាប័ណ្ណខកខានមិនបានបំពេញកាតព្វកិច្ចហិរញ្ញវត្ថុណាមួយរបស់ក្រសួងសេដ្ឋ-កិច្ច និងហិរញ្ញវត្ថុតាមកាលកំណត់ ។

គ.អ្នកទទួលអាជ្ញាប័ណ្ណមិនបានគោរពតាមប្រការ លក្ខខ័ណ្ឌ ឬការដាក់កំរិតរបស់អាជ្ញាប័ណ្ណ

ឃ.អ្នកទទួលអាជ្ញាប័ណ្ណផ្តល់ពត៌មានមិនពិត ឬក្លែងបន្លំ

ង.អ្នកទទួលអាជ្ញាប័ណ្ណខកខានមិនបានផ្តល់បញ្ជីវិភាគគណនី និងឯកសារផ្សេងៗទៀត ដែល ទាក់ទងនឹងការធ្វើអាជីវកម្មកាស៊ីណូតាមសេចក្តីត្រូវការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ច.អ្នកទទួលអាជ្ញាប័ណ្ណ ផ្ទេរកម្មសិទ្ធិអាជ្ញាប័ណ្ណទៅអោយអ្នកផ្សេងទៀតដោយពុំមានការ អនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ឆ.អ្នកទទួលអាជ្ញាប័ណ្ណក្ស័យធនក្នុងការធ្វើអាជីវកម្ម ក្រសួងនឹងចេញបញ្ជាអោយបញ្ឈប់ សកម្មភាពធ្វើអាជីវកម្ម និងអោយធ្វើការទូទាត់បំណុល។

ជ.អ្នកទទួលអាជ្ញាប័ណ្ណបានប្រព្រឹត្តិបទឧក្រិដ្ឋ ឬ ប្រព្រឹត្តិអំពើមិនស្របច្បាប់ណាមួយដែល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយល់ថាជាទង្វើមិនសមស្របជាអ្នកកាន់អាជ្ញាប័ណ្ណ ។

ឈ.អ្នកទទួលអាជ្ញាប័ណ្ណសុំផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្មកាស៊ីណូដោយស្ម័គ្រចិត្ត ។

**ប្រការ ១៥ :** ក្នុងករណីលុបចោល ឬព្យួរទុកអាជ្ញាប័ណ្ណកាស៊ីណូដូចមានចែងក្នុងប្រការ១៤ នៃសារាចរនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងចេញលិខិតជាលាយល័ក្ខអក្សរ ស្តីពីការលុបចោល ឬព្យួរទុក អាជ្ញាប័ណ្ណកាស៊ីណូទៅអោយម្ចាស់អាជ្ញាប័ណ្ណ ដោយបញ្ជាក់ពីមូលហេតុនៃការលុបចោល ឬព្យួរទុក អាជ្ញាប័ណ្ណនោះ ។

បន្ទាប់ពីការលុបអាជ្ញាប័ណ្ណ អ្នកទទួលអាជ្ញាប័ណ្ណត្រូវបញ្ឈប់ជាបន្ទាន់នូវការធ្វើសកម្មភាព អាជីវកម្មកាស៊ីណូ និងសកម្មភាពផ្សេងៗទៀត ហើយអស់សិទ្ធិជាអ្នកកាន់អាជ្ញាប័ណ្ណកាស៊ីណូ ដែល បានចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូក VII

## ការផ្ទេរ និងការលក់អាជ្ញាប័ណ្ណ

**ប្រការ ១៦ :** អ្នកទទួលអាជ្ញាប័ណ្ណមិនត្រូវផ្ទេរ ឬលក់អាជ្ញាប័ណ្ណនេះទៅអោយភាគីណាមួយផ្សេងទៀត ដោយគ្មានការឯកភាពជាលាយល័ក្ខអក្សរពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឡើយ ។ ក្នុងករណីអ្នកទទួលអាជ្ញាប័ណ្ណមានបំណងចង់ផ្ទេរ ឬលក់អាជ្ញាប័ណ្ណនេះទៅអោយភាគីណាមួយនោះ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរ និងបំពេញបែបបទស្នើសុំផ្ទេរ ឬលក់អាជ្ញាប័ណ្ណ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អោយបានមុនរយៈពេលសាមសិបថ្ងៃ (៣០ ថ្ងៃ) គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង និងពាក្យស្នើសុំតទៅ ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានលទ្ធភាពពិនិត្យពិចារណាលើពាក្យស្នើសុំ ហើយត្រូវបង់ប្រាក់ចំនួន ១០០.០០០.០០០,០០រៀលទៀតដូចមានចែងនៅក្នុងប្រការ ១៣ វាក្យខ័ណ្ឌ គ នៃសារាចរណែនាំនេះ ។

## ជំពូក VIII

## ចំណូលកាតព្វកិច្ចកាស៊ីណូ និងអាករផ្សេងៗ

**ប្រការ ១៧ :** ក.ក្រុមហ៊ុនកាស៊ីណូនីមួយៗ ត្រូវបង់ចំណូលកាតព្វកិច្ចជូនរដ្ឋ (ចំណូលលើអាជីវកម្មល្បែងស៊ីសងសុទ្ធសាធ ) ទៅក្នុងគណនីចរិការដ្ឋលេខ 02-35-1211 T023 នៅធនាគារជាតិ នៃកម្ពុជា ឬតាមរយៈសាខាធនាគារកាណាឌីយ៉ាខេត្ត-ក្រុង ក្នុងករណីគ្មានសាខាធនាគារជាតិឈរជើងនៅទីនោះ ទៅតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ខ.នាយកក្រុមហ៊ុនកាស៊ីណូនីមួយៗត្រូវបង់ចំណូលនេះ (ចំណូលកាតព្វកិច្ចកាស៊ីណូ) ប្រចាំខែនៅរៀងរាល់ដើមខែ ដោយមិនអោយហួសពីថ្ងៃទី ០៧ នៃខែ បន្ទាប់ពីខែដែលចំណូលកាស៊ីណូត្រូវបានបង់ ។

**ប្រការ ១៨ :** អាករផ្សេងៗ

ក្រៅពីការបង់ចំណូលកាតព្វកិច្ចដូចមានចែងក្នុងប្រការ១៧ នៃសារាចរនេះ ក្រុមហ៊ុនកាស៊ីណូត្រូវបង់ពន្ធអាករផ្សេងៗទៀត លើសកម្មភាពសេវាក្រៅពីល្បែងទៅតាមច្បាប់សារពើពន្ធ នៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូក IX

## ការផាកពិន័យចំពោះការបង់យឺតយ៉ាវ

**ប្រការ ១៩ :** ១.ចំពោះម្ចាស់អាជ្ញាប័ណ្ណ ឬក្រុមហ៊ុនកាស៊ីណូដែលមិនបានបង់ចំណូលតាមកាលកំណត់ដូចមានចែងក្នុងប្រការ១៧ វាក្យខ័ណ្ឌ " ខ " នៃសារាចរនេះ ប្រាក់ពិន័យបន្ថែមត្រូវកំណត់តាមអត្រា ២ភាគរយ (២%) នៃទឹកប្រាក់បង់យឺត បូកនឹងការប្រាក់២ភាគរយ(២%) នៃទឹកប្រាក់បង់យឺតសំរាប់ខែ ឬ ត្រីមាសនីមួយៗ ។

២.ក្នុងករណីម្ចាស់អាជ្ញាប័ណ្ណ ឬក្រុមហ៊ុនមិនបានបង់ចំណូលក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយពេលបានទទួលលិខិតជូនដំណឹងរំលឹកពីការបង់ចំណូល ប្រាក់ពិន័យបន្ថែមត្រូវកំណត់តាមអត្រា ២៥ភាគរយ (២៥ %) នៃទឹកប្រាក់បង់យឺត បូកនឹងការប្រាក់២ភាគរយ (២%) នៃទឹកប្រាក់ បង់យឺត សំរាប់ខែ ឬ ត្រីមាសនីមួយៗ ។

ការប្រាក់យឺតយ៉ាវត្រូវគិតចាប់ពីថ្ងៃទី ០១ នៃខែ ឬត្រីមាស បន្ទាប់ពីខែ ឬត្រីមាស ដែលត្រូវបង់ ។

## ជំពូក X

## ការត្រួតពិនិត្យ

**ប្រការ ២០ :** ១.ក្នុងរយៈពេលប្រាំពីរថ្ងៃ (០៧ ថ្ងៃ) ក្រោយពីការជូនដំណឹងជាលាយល័ក្ខអក្សរ ឬ ក្នុងករណីចាំបាច់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសិទ្ធិចុះធ្វើការត្រួតពិនិត្យសៀវភៅ បញ្ជីស្នាមនិងឯកសារផ្សេងៗទៀត ដែលជាប់ទាក់ទងនឹងការធ្វើអាជីវកម្មកាស៊ីណូ ដោយមិនកំណត់ពេលវេលា ។

២.អ្នកទទួលអាជ្ញាប័ណ្ណ ឬ នាយកក្រុមហ៊ុនកាស៊ីណូត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការត្រួតពិនិត្យសំណុំឯកសារ ដែលជាប់ទាក់ទងនិងការធ្វើអាជីវកម្មកាស៊ីណូ (Gambling activities) ។

៣.ក្នុងករណីចាំបាច់ និងដើម្បីពង្រឹងនូវប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូលពីកាស៊ីណូ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបញ្ជូនភ្នាក់ងារចុះធ្វើការត្រួតពិនិត្យជាប្រចាំ ឬត្រួតពិនិត្យចៃដន្យទៅលើចំនួនភ្ញៀវ និងចំនួនទឹកប្រាក់ប្តូរកាស់ល្បែង (Chips) ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានលទ្ធភាពក្តាប់អំពីស្ថានភាពចំណូលនៃអាជីវកម្មជាក់ស្តែងរបស់ក្រុមហ៊ុននីមួយៗ ។

៤.ក្រុមហ៊ុនកាស៊ីណូទាំងអស់ត្រូវ ផ្តល់របាយការណ៍ប្រចាំខែមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយបញ្ជាក់អោយបានច្បាស់លាស់អំពី :

-ចំនួនភ្ញៀវចូលលេងល្បែង

-ចំនួនថ្ងៃបើកក្នុងមួយសប្តាហ៍

-ចំនួនប្រាក់ប្តូរកាស់ល្បែង (Chips) ឬផលរបរប្រចាំខែ

-របាយការណ៍នេះត្រូវបញ្ជាក់ថាពិត និងត្រឹមត្រូវដោយនាយកក្រុមហ៊ុន ។

## ជំពូក XI

## សេចក្តីជូនដំណឹង

**ប្រការ ២១ :** សេចក្តីជូនដំណឹងណាមួយដែលបានចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចេញដោយអ្នកទទួលអាជ្ញាប័ណ្ណ ត្រូវធ្វើឡើងជាលាយល័ក្ខអក្សរទៅកាន់អ្នកតំណាងស្របច្បាប់ នៃភាគីពាក់ព័ន្ធដោយ : (១) ហុចជូនដល់ដៃ (២) ឬតាមប្រៃសណីយ៍ (៣) ឬ តាមទូរសារ ។ សេចក្តីជូន

ដំណឹងនេះចាត់ទុកជាបានទទួល :(១) ដោយមានបញ្ជាក់ពេលវេលានៃការទទួលប្រសិនបើផ្តល់អោយផ្ទាល់ដៃ (២) ចុះហត្ថលេខាទទួលបើជាអនុសិដ្ឋ (៣) ឬ នៅពេលដែលបានទទួលច្បាប់ចំលងនៃសេចក្តីជូនដំណឹងនេះតាមទូរសារដោយសុវត្ថិភាពប្រសិនបើផ្ញើតាមទូរសារ ។

## ជំពូក XII

## ច្បាប់គ្រប់គ្រង-ភាសា

**ប្រការ ២២ :** ភាសាផ្លូវការអាជ្ញាប័ណ្ណត្រូវបានគ្រប់គ្រង និងកំណត់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ អាជ្ញាប័ណ្ណត្រូវធ្វើឡើងជាពីរភាសា : គឺភាសាខ្មែរ និងភាសាអង់គ្លេស ។ អត្ថបទជាភាសាខ្មែរជាអត្ថបទផ្លូវការនៃអាជ្ញាប័ណ្ណ ។

**ប្រការ ២៣ :** សារាចរនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ក្រុមការងារចំណូលពិសេស នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាជ្ញាធរខេត្ត-ក្រុង និងក្រុមហ៊ុនកាស៊ីណូទាំងអស់ ត្រូវអនុវត្ត និងប្រតិបត្តិតាមខ្លឹមសារនៃសារាចរ ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះក្រុមហ៊ុនកាស៊ីណូនេះ អោយទទួលបានប្រសិទ្ធភាពខ្ពស់ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

គាត ឈន់

**<u>ចម្លងជូន</u> :**

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាពត៌មាន"

-រតនាគារជាតិ

-នាយកដ្ឋានពន្ធដារ

-គ្រប់ខេត្ត-ក្រុង

"ដើម្បីមុខការ"

-ឯកសារ-កាលប្បវត្តិ